# សន្និបាតបូកសរុបលទ្ធផលការងារពីរឆ្នាំកន្លះ និងទិសដៅការងារបន្ត
# របស់អគ្គាធិការដ្ឋានក្រសួងមុខងារសាធារណៈ

**ឯកឧត្តម បាន់ វណ្ណី អគ្គាធិការ ក្រសួងមុខងារសាធារណៈ**

ថ្ងៃអង្គារ៍ ទី០៥ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃពុធទី០៦ ខែមេសា ឆ្នាំ២០១៦

ក្រសួងមុខងារសាធារណៈ
អគ្គាធិការដ្ឋាន

# មាតិកា

១. សេចក្តីផ្តើម
២. ភារកិច្ច
៣. រចនាសម្ព័ន្ធ
៤. លទ្ធផលសម្រេចបាន
៥. បញ្ហាប្រឈម
៦. សំណូមពរ
៧. សេចក្តីសន្និដ្ឋាន
៨. ទិសដៅការងារបន្តក្នុងឆ្នាំ២០១៦

# ១. សេចក្តីផ្តើម

អគ្គាធិការដ្ឋានជាសេនាធិការផ្ទាល់របស់ក្រសួង ជាភ្នែកជាច្រមុះរបស់ថ្នាក់លើ និងជាមិត្តរបស់ថ្នាក់ក្រោម។ ទន្ទឹមនឹងនេះអគ្គាធិការដ្ឋានបានពង្រឹងប្រសិទ្ធភាពក្នុងការធ្វើអធិការកិច្ច តាមដាន និងត្រួតពិនិត្យលើប្រពន្ធ័គ្រប់គ្រងមុខងារសាធារណៈ នូវរាល់ការអនុវត្តលិខិតបទដ្ឋាន គតិយុត្តិនានា រួមមាន ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ សារាចរណែនាំ សេចក្តីសម្រេចនានា ដល់គ្រប់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងត្រួតពិនិត្យនូវរាល់នីតិវិធីទាំងឡាយដែលច្បាប់បានកំណត់។ ធ្វើអធិការកិច្ចលើវិវាទពាក់ពន្ធ័មុខងារសាធារណៈ ធ្វើការសន្និដ្ឋាននិងវាយតម្លៃចំពោះការងារ ដែលក្រសួង ស្ថាប័នបានអនុវត្តកន្លងមក។

# ២. ភារកិច្ច

## អគ្គាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម៖

- ធ្វើអធិការកិច្ចដើម្បីប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ត្រួតពិនិត្យរដ្ឋបាលស្តីពីការគ្រប់គ្រងមន្ត្រីរាជការលើការគោរពនូវរាល់នីតិវិធីអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ
- ធ្វើអធិការកិច្ចលើវិវាទពាក់ព័ន្ធនឹងមុខងារសាធារណៈ
- ផ្តល់យោបល់ដល់ប្រធានអង្គភាពរដ្ឋបាលនៃក្រសួង/ស្ថាប័ន លើ បញ្ហាគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋ ក្នុងករណីដែលមានការខ្វះខាតក្នុងការអនុវត្តគោលការណ៍

# ២. ភារកិច្ច (ត)

## អគ្គាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម៖

- បំពេញភារកិច្ចអធិការកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ឲ្យ
- រាយការណ៍អំពីលទ្ធផលនៃការធ្វើអធិការកិច្ចជូនរដ្ឋមន្ត្រី
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

# រចនាសម្ព័ន្ធ

**អគ្គាធិការ**

↓

**អគ្គាធិការរង**

↓

**អធិការ**

↓

- **ការិយាល័យ** រដ្ឋបាល
- **ការិយាល័យ** អធិការកិច្ចមុខងារសាធារណៈ
- **ការិយាល័យ** អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ

# ៤. លទ្ធផលសម្រេចបាន

- បានចុះស្រាវជ្រាវករណីមិនប្រក្រតីនៃការដាក់មន្ត្រីឲ្យចូលនិវត្តន៍និងបានរកឃើញការក្លែងបន្លំឯកសារ និងបានដោះស្រាយសម្របសម្រួលដាក់ឲ្យចូលនិវត្តន៍តាមនីតិវិធី

- បានចុះស្រាវជ្រាវករណីមិនប្រក្រតីរបស់មន្ត្រីរាជការនិងបានរកឃើញសាមីខ្លួនបានកែបន្លយអាយុចូលនិវត្តន៍ លើសលាកបត្រពត៌មាន ករណីនេះត្រូវបានដាក់ឲ្យសាមីខ្លួនចូលនិវត្តន៍ និងបង្វែរថវិកាចូលរដ្ឋវិញ

- បានចុះស្រាវជ្រាវបណ្តឹងអនាមឹកស្តីពីភាពមិនប្រក្រតីក្នុងការប្រឡងផ្លាស់ប្តូរក្របខណ្ឌសរបស់មន្ត្រីរាជការនិងពុំបានរកឃើញភាពមិនប្រក្រតីដូចការចោទប្រកាន់នោះទេ

# ៤.លទ្ធផលសម្រេចបាន(ត)

- បានពិនិត្យនិងដោះស្រាយបណ្ដឹងជូនមន្ត្រីរាជការក្នុងការផ្លាស់ប្ដូរតួនាទី និងមុខតំណែង សាមីខ្លួនមានការឯកភាព ទទួលយកតាមការសម្រប សម្រួលរួចហើយ

- បានពិនិត្យ សិក្សាស្រាវជ្រាវនិងដោះស្រាយករណីលុបឈ្មោះមន្ត្រីរាជការ ចំនួន០២នាក់ ចេញពីក្របខណ្ឌរដ្ឋ ត្រឹមត្រូវតាមនីតិវិធីជាធរមាន

- បានពិនត្យសិក្សាស្រាវជ្រាវនិងដោះស្រាយករណីផ្ទេរភារកិច្ចនិងកន្លែងធ្វើការរបស់មន្ត្រីរាជការ ចំនួន០២នាក់ ស្របតាមនីតិវិធីជាធរមាន

# ៤.លទ្ធផលសម្រេចបាន(ត)

- បានពនិត្យ ស្រាវជ្រាវ និងដោះស្រាយករណីតែងតាំងប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ អនុវត្តខុសនីតិវិធី ករណីនេះក្រសួងមុខងារសាធារណៈបានណែនាំឲ្យអនុវត្តតាមនីតិវិធីនៃការតែងតាំងដែលនៅជាធរមាន

- បានពិនិត្យ និងដោះស្រាយវិវាទមុខងារសាធារណៈក្នុងការតែងតាំងប្រធានមណ្ឌលសុខភាពជាលទ្ធផលសាមីខ្លួនទាំងពីរបានទទួលយកតាមការដោះស្រាយរួចហើយ

- បានពិនិត្យ និងសិក្សាស្រាវជ្រាវករណីកែឆ្នាំកំណើតរបស់មន្ត្រីរាជការករណីនេះសាមីខ្លួនបានទទួលស្គាល់ថាបានកែអាយុពិតប្រាកដមែន និងបានបញ្ចប់ដោយដាក់ឲ្យចូលនិវត្តន៍តាមនីតិវិធី

# ៤.លទ្ធផលសម្រេចបាន(ត)

- បានចុះធ្វើអធិការកិច្ចមន្ត្រីរាជការ០២នាក់ ដែលមានឈ្មោះស្ទួន ក្នុងតារាងទូទាត់បៀវត្ស និងបានលុបឈ្មោះមួយចេញពីតារាងទូទាត់បៀវត្ស ព្រមទាំងឱ្យបង្វែរថវិកាចូលរដ្ឋវិញ បានចំនួន០២ករណី

- បានចុះធ្វើអធិការកិច្ចមន្ត្រីរាជការ០១នាក់ ដែលមានឈ្មោះ០២កន្លែង ក្នុងតារាងទូទាត់បៀវត្ស និងបានឲ្យលុបឈ្មោះមួយចេញពីតារាងទូទាត់បៀវត្ស   ព្រមទាំងឱ្យបង្វែរថវិកាចូលរដ្ឋវិញ

# ៤.១ ចូលរួមវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលស្តីពីឧត្តមានុវត្តសម្រាប់ពង្រឹងគុណផល
ការងារ នៅប្រទេសម៉ាឡេស៊ី (វិច្ឆិកា, ២០១៤)
(Best Practice for Enhancing Performance)



វគ្គបណ្តុះបណ្តាលអធិការកិច្ច នៅប្រទេសវៀតណាម
(មករា, ឆ្នាំ២០១៦) (Training of Inspection)



# ៤.២ សកម្មភាពផ្សេងៗ



សកម្មភាពចុះត្រួតពិនិត្យក្របខ័ណ្ឌគ្រូបង្រៀន គ្រូជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់២វេន និងថ្នាក់គួប នៅខេត្តកំពង់ចាម  កំពង់ធំ  និងព្រះវិហារ





# ៥. បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបានរយៈពេលកន្លងមក អគ្គាធិការដ្ឋានក៏បាននឹងកំពុងជួបប្រទះនូវបញ្ហាមួយចំនួនផងដែរ ក្នុងនោះរួមមាន៖

- ធនធានមនុស្សនៅមានកម្រិត៖
  - ចំណេះដឹង (អធិការកិច្ច ការគ្រប់គ្រងរដ្ឋបាលសាធារណៈ ភាពជាអ្នកគ្រប់គ្រង)
  - អាកប្បកិរិយា (ការទទួលខុសត្រូវក្នុងការងារ ការចូលរួមមនសិការវិជ្ជាជីវៈ ឆន្ទៈ និងអភិវឌ្ឍសមត្ថភាព)
- ការសហការមិនទាន់បានរលូនរវាងក្រុមការងារនិងមុខសញ្ញាអធិការកិច្ច

# ៥. បញ្ហាប្រឈម(ត)

- ខ្វះខាតសម្ភារៈសម្រាប់បំរើការងារនៅមិនទាន់គ្រប់គ្រាន់
(ដូចជា៖ កុំព្យូទ័រ  ម៉ាស៊ីនហ្វូតូកូពី ទូរស័ព្ទ តុ កៅអី...)

- មធ្យោបាយសម្រាប់ធ្វើដំណើរក្នុងការងារចុះអធិការកិច្ច (រថយន្ត)

# ៦. សំណូមពរ

ដើម្បីសំរេចបាននូវគោលបំណងគោលនយោបាយ ក៏ដូចជាកម្មវិធីដែលក្រសួងបានកំណត់ ហើយអង្គភាពនិមួយៗត្រូវអនុវត្តតាមវិស័យរៀងៗខ្លួននោះ  អគ្គាធិការដ្ឋានសូមសំណូមពរដូចខាងក្រោម៖

- បណ្តុះបណ្តាលមន្ត្រីក្នុងអង្គភាពជាអាទិភាព និងតម្រែតម្រង់ទិសក្នុងការងារអធិការកិច្ច
- ផ្តល់ការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីលើជំនាញនានារបស់អគ្គាធិការដ្ឋាន  ជាពិសេសការងារអធិការកិច្ច
- ផ្តល់សំភារៈគ្រប់គ្រាន់សម្រាប់ដំណើរការងារ (ដូចជា៖ កុំព្យូទ័រ ម៉ាស៊ីនហ្វូតូកូពី  ទូរស័ព្ទ  តុ  កៅអី...)

# ៦. សំណូមពរ(ត)

- យន្តការលើកទឹកចិត្តដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងមនសិការវិជ្ជាជីវៈ
- មធ្យោបាយធ្វើដំណើរសម្រាប់ការងារចុះធ្វើអធិការកិច្ច (រថយន្ត)

# ៧. សន្និដ្ឋាន

រយៈពេលពីរឆ្នាំកន្លះដោយមានការចង្អុលបង្ហាញ ប្រកបដោយភាពវៃឆ្លាត របស់ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អគ្គាធិការដ្ឋានបានបំពេញការងារ និងសម្រេចបានលទ្ធផលគួរជាទីមោទនៈតាមលទ្ធភាពធនធានដែលមាន ក្នុងនោះការងារចុះអធិការកិច្ចនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបានចំនួន១៥ករណី។ លទ្ធផលនេះឆ្លើយតបទៅនឹងផលប្រយោជន៍មន្ត្រីរាជការ ក៏ដូចជាក្រសួង ស្ថាប័ន។ អគ្គាធិការដ្ឋាននឹងបន្តអនុវត្តការងារទៅតាមមុខងាររបស់ខ្លួន និងបំពេញភារកិច្ចនានាដែលថ្នាក់ដឹកនាំប្រគល់ជូន ឲ្យបានខ្ជាប់ខ្ជួន ដើម្បីសម្រេចបាននូវលទ្ធផលល្អប្រសើរ។ រួមចំណែកអនុវត្តន៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

# ៨. ទិសដៅការងារបន្តក្នុងឆ្នាំ២០១៦

- បន្តរំកិលសកម្មភាព២០១៥ មកបញ្ចូលក្នុងផែនការសកម្មភាព២០១៦
- បន្តធ្វើផែនការឆ្នាំ២០១៦របស់អគ្គាធិការដ្ឋាន
- បន្តធ្វើអធិការកិច្ចតាមក្រសួងស្ថាប័នទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
    - ដាក់ឲ្យចូលនិវត្តន៍ចំពោះមន្ត្រីដែលបាត់បង់កាយសម្បទាវិជ្ជាជីវៈ
    - ការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
    - វិសមិត្តភាពការងារ
    - វិវាទមុខងារសាធារណៈ
    - ចុះពិនិត្យមន្ត្រីរាជការដែលបើកបៀវត្ស០២កន្លែង
    - ការដាក់មន្ត្រីតាមប្រភេទក្របខណ្ឌនិមួយៗដែលគ្រប់អាយុឲ្យចូល
    - និវត្តន៍ដោយអនុវត្តតាមសារាចរណែនាំ០១ចុះថ្ងៃ១២/០៤/០៩

# ៨. ទិសដៅការងារបន្តក្នុងឆ្នាំ២០១៦ (ត)

- ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលតាមក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បន្តសិក្សាស្រាវជ្រាវប្រមូលចងក្រងឯកសារពាក់ពន្ធ័នឹងការងារអធិការកិច្ចវិស័យមុខងារសាធារណៈ
- ត្រៀមលក្ខណៈចូលរួម និងបញ្ជូនមន្ត្រីក្នុងអគ្គាធិការដ្ឋាន ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាល វគ្គសិក្ខាសាលា កិច្ចប្រជុំ កម្មវិធីផ្សេងៗ និងគម្រោងនានាដែលរៀបចំដោយក្រសួងមុខងារសាធារណៈ ឬក្រសួង ស្ថាប័ន អង្គភាពដែលពាក់ពន្ធ័
- នឹងពិចារណាតាមផ្លូវច្បាប់ ហើយស្នើសុំឲ្យអគ្គាធិការដ្ឋាននៃក្រសួងស្ថាប័នផ្តល់របាយការណ៍អំពីការងារអធិការកិច្ចរបស់ខ្លួនមកអគ្គាធិការដ្ឋានម.ស.រ

# ៨. ទិសដៅការងារបន្តក្នុងឆ្នាំ២០១៦(ត)

- ស្រាវជ្រាវនិងចងក្រងប្រវត្តិការណ៍របស់អគ្គាធិការដ្ឋានមុខងារសាធារណៈក្នុងដំណាក់កាលព្រះរាជាណាចក្រកម្ពុជាទី២
- ត្រៀមលក្ខណៈក្នុងការបំពេញភារកិច្ចផ្សេងទៀតតាមបទបញ្ជាដែលថ្នាក់ដឹកនាំប្រគល់ជូន។

# សូមអរគុណ